# វិធានការទប់ស្កាត់ និងកម្ចាត់ សមាសភាពចង្រៃលើដំណាំធុរេន



រៀបរៀងដោយ៖ នាយកដ្ឋានការពារដំណាំ អនាម័យ និងភូតគាមអនាម័យ
នៃអគ្គនាយកដ្ឋានកសិកម្ម

ឆ្នាំ ២០២២

# វិធានការទប់ស្កាត់ និងកម្ចាត់ សមាសភាពចង្រៃលើដំណាំទុរេន




រៀបរៀងដោយ: នាយកដ្ឋានការពារដំណាំអនាម័យ និងភូតគាមអនាម័យ

អគ្គនាយកដ្ឋានកសិកម្ម



ឆ្នាំ២០២២

## មាតិកា


**១. សត្វល្អិតចង្រៃចំបងៗលើដំណាំទុរេន**

១.១ ទ្រីប ........ ១

១.២ ចៃម្សៅ ........ ៣

១.៣ កញ្ចៃស៊ីស្លឹក ........ ៥

១.៤ ម៉ែត៍ក្រហមអាហ្វ្រិច ........ ៧

១.៥ ដង្កូវចោះផ្លែទុរេន ........ ៩

១.៦ ដង្កូវចោះគ្រាប់ទុរេន ........ ១១

១.៧ ដង្កូវស៊ីរូងដើមទុរេន ........ ១៣

**២. ជំងឺចំបងៗលើដំណាំទុរេន**

២.១ ជំងឺដំបៅដើម ........ ១៥

២.២ ជំងឺផ្សិតហ្វូម៉ូស៊ីសរលាកស្លឹក ........ ១៧

២.៣ ជំងឺកុលាប ........ ១៩

២.៤ ជំងឺរលួយឫស ........ ២០

២.៥ ជំងឺផ្សិតអង់ត្រាណូសស្លឹកទុរេន ........ ២៣

**៣. ឯកសារយោង** ........ ២៥



ទ.៣.ឌ.... AIDOC
Date
Donated by:

# សមាសភាពចង្រៃលើដំណាំទុរេន

## ១. សត្វល្អិតចង្រៃចំបងៗលើដំណាំទុរេន

### ១.១ ទ្រីប

**ឈ្មោះទូទៅជាភាសាខ្មែរ** ៖ ទ្រីប

**ឈ្មោះទូទៅជាភាសាអង់គ្លេស** ៖ Thrips

**ឈ្មោះវិទ្យាសាស្ត្រ** ៖ *Thrips coloratus* Schmutz, *Thripsha waiiensis* Morgan

**លក្ខណៈរូបសាស្ត្រ**

- ទ្រីបជាសត្វល្អិតចង្រៃបន្ទាប់បន្សំនៅលើដើមទុរេន ជាទូទៅវាមានទំហំ ០.៥-២មីលីម៉ែត្រ និងមានប្រវែងរហូតដល់១៤មីលីម៉ែត្រ
- សត្វញីជាទូទៅមានពណ៌លឿង និងនៅផ្នែកពោះមានឆ្នូតពណ៌ត្នោតក្រម៉ៅនៅចំកណ្តាល
- សត្វញីធ្វើការទំលាក់ពងនៅក្នុងកោសិកាស្លឹករុក្ខជាតិដោយបំពង់ Ovipositor របស់វា
- កូនញាស់ និងសត្វពេញវ័យជញ្ជក់យករុក្ខរសពីកោសិកាស្លឹករុក្ខជាតិ ដែលធ្វើឱ្យស្លឹកមានស្នាមបំផ្លាញត្រង់កន្លែងជញ្ជក់នោះ
- ពងបានអាយុចាប់ពី២-៣ថ្ងៃ កូនដង្កូវចាប់ផ្តើមញាស់ និងអាចរស់បានរយៈពេលប្រមាណ ៤៥ថ្ងៃ



## លក្ខណៈបំផ្លាញ

- ទ្រីបបឺតយករុក្ខរសពីផ្កា ស្លឹក និងដើម ដែលជាទូទៅមិនមានការបំផ្លាញធ្ងន់ធ្ងរណាមួយកើតឡើងនោះទេ
- ចំពោះស្លឹកការបំផ្លាញរបស់វាអាស្រ័យទៅលើចំនួនប្រជាករសត្វល្អិតដែលបំផ្លាញ ប្រសិនបើមានចំនួនប្រជាករច្រើន វាអាចធ្វើឱ្យស្លឹកទុរេនមិនអាចធ្វើរស្មីសំយោគបាន
- ប្រសិនបើកម្រិតនៃការបំផ្លាញខ្លាំង វាចេញរោគសញ្ញាដូចជា៖ ស្លឹកមានស្នាមអុចៗតូចពណ៌លឿង ខូចទ្រង់ទ្រាយ ជួនកាលអាចទៅជារួញ ហើយចំពោះផ្កាប្រែទៅជាពណ៌ប្រផេះប្រាក់ ឬខ្មៅ និងមានស្នាមអុចៗផងដែរ។



## វិធានការគ្រប់គ្រង និងកម្ចាត់

- ២-៣ថ្ងៃ តាមដានវត្តមានទ្រីបឱ្យបានទៀងទាត់ ជាពិសេសនៅដំណាក់កាល ចេញត្រួយ ផ្កា និងផ្លែ
- សម្រាប់ការតាមដានវត្តមានទ្រីប អាចប្រើប្រាស់អន្ទាក់ស្អិតពណ៌លឿងនៅក្នុងចំការ ពិនិត្យនៅលើស្លឹកខ្ចី និងផ្កា។
- មិនត្រូវផ្តល់សារធាតុចិញ្ចឹមដែលមានកម្រិតជីអាសូតច្រើននោះទេ
- ក្នុងករណីដែលមានការបំផ្លាញច្រើនយើងអាចប្រើប្រាស់ថ្នាំកសិកម្មដែលមានសារជាតុសកម្មដូចជា៖ Acetamiprid, Acephate, Carbaryl,

Imidacloprid, Deltamethrin, lambda-Cyhalothrin, Thiamethoxam, Dinotefuran, Spinosad។

## ១.២ ចៃម្សៅ

**ឈ្មោះទូទៅជាភាសាខ្មែរ** ៖ ចៃម្សៅ

**ឈ្មោះទូទៅជាភាសាអង់គ្លេស** ៖ Mealy Bug

**ឈ្មោះវិទ្យាសាស្ត្រ** ៖ *Planococcus lilacinus* (Cockerell), *Planococcus minor* (Maskell)

### លក្ខណៈរូបសាស្ត្រ

- មេរបស់ចៃម្សៅមានប្រវែងប្រហែល ៣ម.ម ដែលខ្លួនរបស់វាមានពណ៌លឿង ឬផ្កាឈូក គ្រប់ដណ្តប់ដោយកំទេចម្សៅពណ៌ស
- ពងរបស់ចៃម្សៅមានរាងពងក្រពើ ពណ៌ទឹកក្រូច រុំព័ទ្ធដោយសំឡីគ្រប លើពង និងមានប្រវែង ០,៣ម.ម
- សត្វញីអាចពងចន្លោះពី៦០០-៨០០ពង ដែលពងដាក់នៅលើស្លឹក ផ្លែ ឬមែក ដោយផ្ទុកនៅក្នុងថង់ពង
- សត្វញីដែលទើបនឹងញាស់មានពណ៌លឿងស្រាល
- ពងញាស់ក្នុងរយៈពេល ៦-១០ថ្ងៃ និងសត្វញីសក៣ដង, ឈ្មោលសក ៤ដង

### លក្ខណៈបំផ្លាញ

- កូនញាស់ និងចៃពេញវ័យរស់នៅជាក្រុម
- បឺតយករុក្ខរសពី ស្លឹក កញ្ចុំផ្កា ផ្លែខ្ចី និងផ្លែទុំ
- ទឹកដមដែលមានជាតិផ្អែមនិងស្អិតរបស់ចៃម្សៅ ដែលមាននៅលើស្លឹក និងផ្លែ ដែលជាហេតុបណ្តាលឱ្យមានការកើតឡើងនូវជំងឺផ្សិតម្សៅខ្មៅ (Sooty mold)

- ប្រសិនបើផ្សិតនោះកើតឡើងនៅលើស្លឹក ហើយមានវត្ថុមានច្រើននោះ វានឹងកាត់បន្ថយការធ្វើរស្មីសំយោគ ដែលជាហេតុក្នុងការកាត់បន្ថយការលូតលាស់របស់ដំណាំទុរេន។ ហើយបើផ្សិតនោះមាននៅលើផ្លែនោះវានឹងកាត់បន្ថយនូវតម្លៃទីផ្សារ។






**វិធានការគ្រប់គ្រង និងកម្ចាត់**

- ធ្វើការសម្អាតស្មៅចង្រៃនៅជុំវិញគល់ដំណាំឱ្យបានស្អាតនៅចុងរដូវវស្សា
- កាត់ចេញនូវផ្នែកដែលរងការបំផ្លាញធ្ងន់ធ្ងរពីចៃម្សៅ ដូចជាផ្លែ មែក យកទៅដុតបំផ្លាញចោល
- បាញ់ទឹកជាមួយក្បាលម៉ាស៊ីនដែលមានសម្ពាធខ្ពស់ ដើម្បីឱ្យធ្លាក់នូវពពួកចៃម្សៅ
- ក្នុងករណីដែលមានការបំផ្លាញច្រើនយើងអាចប្រើប្រាស់ថ្នាំកសិកម្មដែលមានសារធាតុសកម្មដូចជា៖ Cypermethrin, Deltamethrin, lambda-Cyhalothrin, Thiamethoxam, Dinotefuran, Butocarboxim។ ដើម្បីបង្កើនប្រសិទ្ធរបស់ថ្នាំ ឬសម្លាប់សត្វល្អិតចង្រៃអាចប្រើលាយជាមួយប្រេងជម្រាប។

## ១.៣ កញ្ចែស៊ីស្លឹក

**ឈ្មោះទូទៅជាភាសាខ្មែរ** ៖ កញ្ចែស៊ីស្លឹក

**ឈ្មោះទូទៅជាភាសាអង់គ្លេស** ៖ Swarming leaf beetle

**ឈ្មោះវិទ្យាសាស្ត្រ** ៖ *Ryparida* spp., *Bactocera gultata, Zeuzera coffea* និង *Symanthoden* spp.

### លក្ខណៈរូបសាស្ត្រ

- ជាប្រភេទសត្វល្អិតចង្រៃដ៏ចម្បងនៅតាមឆ្នេរនៃតំបន់ត្រូពិច
- ជាទូទៅនៅពេលដើមរដូវវស្សា សត្វពេញវ័យនឹងចេញពីក្នុងដី ហើយចាប់ផ្តើមធ្វើការបំផ្លាញ
- សត្វពេញវ័យមានទំហំតូចប្រមណពី ៣ ទៅ ៥ម.ម ដែលមានពណ៌ខ្មៅ ឬត្នោតរលើប
- ចំពោះសត្វញីធ្វើការទំលាក់ពងនៅក្នុងដី បន្ទាប់មកញាស់ជាកូនដង្កូវតូចៗដែលមានពណ៌ស
- កូនដង្កូវតូចៗ ចាប់ផ្តើមចិញ្ចឹមខ្លួនវាដោយវាស៊ីឬសស្មៅក្នុងរយៈពេល ២ ទៅ ៣ខែ មុនពេលវិវឌ្ឍន៍ទៅជាដុកឌឿ
- នៅពេលភ្លៀងខ្លាំង កូនដង្កូវញាស់ចាប់ផ្តើមធ្វើការបំផ្លាញខ្លាំង ដែលជាទូទៅក្នុងមួយឆ្នាំវាអាចមាន២-៣ជំនាន់





**លក្ខណៈបំផ្លាញ**

- វាធ្វើការបំផ្លាញទៅលើដំណាំជាច្រើនដូចជា ទុរេន សាវម៉ាវ មៀន ខ្នុរ និងចំប៉ាដក់ជាដើម
- ចំពោះស្លឹករបស់ដំណាំ វាធ្វើឱ្យមានស្នាមឆេះខ្លោច និងធ្លុះធ្លាយ ដែលធ្វើឱ្យការលូតលាស់កូនដំណាំត្រូវបានបង្អាក់ ព្រមទាំងធ្វើឱ្យប៉ះពាល់ក្នុងវគ្គចេញផ្លែផ្កា
- ចំពោះហ្វូងសត្វល្អិត អាចបង្កការខូចខាតខ្លាំង ដល់ដំណាំលូតលាស់ថ្មី និងជួនកាលអាចប៉ះពាល់ទៅដល់ ការលូតលាស់របស់ផ្លែ
- ចំពោះមេពេញវ័យភាគច្រើនតែងតែធ្វើការស៊ីបំផ្លាញនៅពេលយប់






**វិធានការគ្រប់គ្រង និងកម្ចាត់**

- យើងអាចសង្កេតមើលការបំផ្លាញរបស់ពួកវាក្នុងដំណាក់កាលកូនទុរេននៅតូច ជាពិសេសនៅរដូវភ្លៀង។
- ត្រូវត្រួតពិនិត្យជាប្រចាំនៅក្រោយដំណាក់កាលលូតលាស់ត្រួយ ដើម្បីដឹងពីវត្តមាននៃការបំផ្លាញដំបូង។
- ក្នុងករណីមានការបំផ្លាញធ្ងន់ធ្ងរយើងអាចកំចាត់ពួកវាដោយប្រើថ្នាំកសិកម្មដែលមានធាតុសកម្មដូចជា៖ Dimethoate, Chlorpyrifos, Cypermethrin, Carbaryl, Imidaclorprid

## ១.៤ ម៉ែត៍ក្រហមអាហ្រ្វិច

**ឈ្មោះទូទៅជាភាសាខ្មែរ** ៖ ម៉ែត៍ក្រហមអាហ្រ្វិច

**ឈ្មោះទូទៅជាភាសាអង់គ្លេស** ៖ African red mite

**ឈ្មោះវិទ្យាសាស្ត្រ** ៖ *Eutetranychus africanus* (Tucker)

**លក្ខណៈរូបសាស្ត្រ**

- ម៉ៃក្រហម គឺជាសត្វល្អិតចង្រៃតូចៗដ៏សំខាន់មួយនៅលើដំណាំទុរេន ដែលពិបាកក្នុងការមើលដោយភ្នែកទទេ
- ដើម្បីឃើញវត្តមានសត្វប្រភេទនេះ យើងត្រូវគោះស្លឹកដែលរងការបំផ្លាញនៅលើក្រដាសពណ៌ស ឬកែវពង្រីក
- សត្វញីមានរាងមូល ទំហំ០,៣-០,៤មីលីម៉ែត្រ, ទទឹង ០,៣មីលីម៉ែត្រ និងមានពណ៌ក្រហមក្រម៉ៅ ឬត្នោតក្រម៉ៅ ដែលជាទូទៅវាអាចរស់បានប្រមាណ ៨ថ្ងៃ ក្រោយពីការទំលាក់ពង
- សត្វឈ្មោលរបស់មានពណ៌ត្នោតខ្ចី និងមានទំហំតូចជាងសត្វញី ដែលជាទូទៅវាអាចរស់បានប្រមាណ ៣៦ម៉ោង
- ការបង្កកំណើតចាប់ផ្តើមនៅពេលដែលសត្វឈ្មោលបញ្ឈប់ការសក ហើយក្លាយទៅជាសត្វពេញវ័យ បន្ទាប់មក វាចាប់ផ្តើមរកសត្វញីដែលស្ថិតក្នុងដំណាក់កាលទីបីនៃដំណាក់កាលដង្កូវ ហើយវារងចាំដល់ដំណាក់កាលសក ចុងក្រោយរបស់សត្វញី
- បន្ទាប់ពីការបង្កកំណើតបាន១-២ថ្ងៃ សត្វញីនឹងចាប់ផ្តើមបង្កើតពង
- ការលូតលាស់រវាងសត្វញីនិងឈ្មោលមានរយៈពេល ៩ថ្ងៃ ដែលរួមបញ្ចូលទាំងដំណាក់កាលពង និងប្រមាណ ៣៦ម៉ោង សម្រាប់វគ្គដង្កូវទាំង៣វគ្គ
- ការទំលាក់ពងជាមធ្យម បាន១៤ពង




## លក្ខណៈបំផ្លាញ

- វាបំផ្លាញដោយបឺតយករុក្ខរសពីស្លឹកនៅផ្នែកខាងលើ
- ស្លឹកដែលរងការបំផ្លាញមានស្នាមអុចតូចៗពណ៌ស បន្ទាប់មកប្រែជាស្លក ខុសពីស្លឹកធម្មតា
- ប្រសិនបើមានការបំផ្លាញខ្លាំងធ្វើឱ្យស្លឹកជ្រុះ ហើយធ្វើឱ្យប៉ះពាល់ដល់ការលូតលាស់របស់ផ្កា និងផ្លែ





## វិធានការគ្រប់គ្រង និងកម្ចាត់

- ធ្វើការសំអាតស្មៅចេញពីចំការ ដោយសារពពួកម៉ៃត៍នេះវាអាចលាក់ខ្លួននៅក្នុងស្មៅបាន
- តាមដានវត្តមានសត្វល្អិតម៉ៃត៍ជាប្រចាំ ដោយសង្កេតនៅលើស្លឹករុក្ខជាតិជាពិសេសនៅពេលដែលចាប់ផ្តើមធ្លាក់ភ្លៀង ក្នុងកំឡុងខែកញ្ញា និងតុលា

- ក្នុងករណីដែលមានការបំផ្លាញច្រើនយើងអាចប្រើប្រាស់ថ្នាំកសិកម្ម ដែលមានសារធាតុសកម្មដូចជា Propargite, Spiromesifen, Chlorfenapyr, Dimethoate, Fenothiocarb និង Amitraze

## ១.៥ ដង្កូវចោះផ្លែទុរេន

**ឈ្មោះទូទៅជាភាសាខ្មែរ** ៖ ដង្កូវចោះផ្លែទុរេន

**ឈ្មោះទូទៅជាភាសាអង់គ្លេស** ៖ Durian fruit borer

**ឈ្មោះវិទ្យាសាស្ត្រ** ៖ *Conogethes punctiferalis*

### លក្ខណៈរូបសាស្ត្រ

- មេអំបៅពេញវ័យ មានពណ៌លឿង លាយជាមួយស្នាមអុចតូចៗពណ៌ត្នោតក្រម៉ៅនៅលើស្លាប ទំហំ១២ម.ម
- មេអំបៅពេញវ័យស្លាបរបស់វាលាតសន្ធឹងប្រវែងពី ២.០ ទៅ ២.៣ស.ម
- មេអំបៅពេញវ័យទំលាក់ពងនៅលើផ្លែទុរេន ហើយពងនោះនឹងញាស់ក្នុងរយៈពេល ៤ថ្ងៃក្រោយពីការដាក់ពង
- កូនដង្កូវមានពណ៌ស និងក្បាលមានពណ៌ត្នោត វាស៊ីចំណីនៅលើសំបកនៃផ្លែទុរេន
- ក្រោយពីធ្វើការចោះចូលទៅក្នុងផ្លែរួចវាស៊ីបំផ្លាញផ្លែ ហើយខ្លួនវាប្រែទៅជាពណ៌ត្នោតខ្ចី និងមានស្នាមអុចពណ៌ ត្នោតក្រម៉ៅ ឬខ្មៅនៅលើដងខ្លួនរបស់វា
- បន្ទាប់ពី ១២ ទៅ ១៣ថ្ងៃក្រោយមក វានឹងក្លាយទៅជាដុកឌឿ ដែលយើងសង្កេតឃើញមានស្លឹកនិងអាចម៍ដង្កូវនៅ ព័ទ្ធជុំវិញដុកឌឿ ជាទូទៅដំណាក់កាលជាដុកឌឿ វាមានរយៈពេលពី ៧ ទៅ៩ថ្ងៃ និងក្រាំងនៅក្នុងដីជម្រៅ ២.៥-១៧.៥ ស.ម

- អាចពងបានប្រមាណ១០០-២០០ពង និងដង្កូវមានប្រវែង១.៥-១.៨ ស.ម





## លក្ខណៈបំផ្លាញ

- ដង្កូវធំៗចូលចិត្តស៊ីលើផ្នែកបន្តពូជរុក្ខជាតិដូចជា ពន្លកផ្កា ផ្កា និងផ្លែខ្ចី
- កូនញាស់ និងដង្កូវពេញវ័យស៊ីចោះផ្លែ បណ្តាលឱ្យផ្លែស្អុយរលួយ
- ចំពោះផ្លែដែលជាប់គ្នា ជាទីតាំងល្អសម្រាប់ឱ្យមេអំបៅទំលាក់ពង
- រន្ធដែលចោះដោយដង្កូវអាចបណ្តាលឱ្យកើតជម្ងឺ Phytophthora ដែលអាចបណ្តាលឱ្យមានការរលួយផ្លែ និងជ្រុះផ្លែផងដែរ។



## វិធានការគ្រប់គ្រង និងកម្ចាត់

- តាមដានវត្តមានមេអំបៅ និងដង្កូវ ដោយសង្កេតមានអាចម៍ដង្កូវដែលអាចមើលឃើញនៅលើសំបកខាងក្រៅ
- ប្រើអន្ទាក់ពន្លឺ ដើម្បីកាត់បន្ថយចំនួនមេអំបៅពេញវ័យ

- ដុត ឬកប់ផ្លែដែលខូច ឬជ្រុះ
- កាត់ផ្លែដែលនៅជាប់ឱ្យនៅតែមួយ ព្រោះមេអំបៅពេញវ័យចូលចិត្តពង នៅលើសំបករវាងផ្លែឈើដែលនៅជាប់គ្នា។ បើមិនដូច្នេះទេ ត្រូវញែក ផ្លែឈើដែលនៅជាប់គ្នាដោយដាក់ឈើឬសម្ភារៈណាមួយនៅចន្លោះ ពួកវា
- ប្រើថង់ប្លាស្ទិចខ្ចប់ផ្លែ នៅពេលផ្លែអាយុបាន២-៣សប្តាហ៍ ដោយប្រើ ថង់ប្លាស្ទិចដែលមានរន្ធដើម្បីបង្ហូរទឹក ថង់នឹងការពារមេអំបៅញីពីការ ពងនៅលើសំបក។ ដកថង់ទាំងនេះចេញ២សប្តាហ៍មុនពេលប្រមូល ផលពីព្រោះផ្លែឈើ
ដែលវេចខ្ចប់មានពណ៌ស្លេកខុសពីធម្មជាតិ។
- ក្នុងករណីមានការបំផ្លាញធ្ងន់ធ្ងរយើងអាចកម្ចាត់ដោយប្រើថ្នាំកសិកម្ម ដែលមានសារធាតុសកម្ម Dimethoate, Emamectin benzoate, Lamda-cyhalothrin, Deltamethrin, Chlorpyrifos, Bacillus thuringiensis var. kurstaki ។

## ១.៦ ដង្កូវចោះគ្រាប់ទុរេន

**ឈ្មោះទូទៅជាភាសាខ្មែរ** ៖ ដង្កូវចោះគ្រាប់ទុរេន

**ឈ្មោះទូទៅជាភាសាអង់គ្លេស** ៖ Durian seed borer

**ឈ្មោះវិទ្យាសាស្ត្រ** ៖ *Mudaria luteileprosa* Holloway

### លក្ខណៈរូបសាស្ត្រ

- មេអំបៅពេញវ័យរបស់ដង្កូវចោះផ្លែអាចទំលាក់ពងបានពី ១០០-២០០ពង
- កូនញាស់របស់ដង្កូវនេះចាប់ផ្តើមញាស់ក្នុងរយៈពេល ១០ថ្ងៃ បន្ទាប់ពី ពេលទំលាក់ពង ហើយវាត្រូវការពេលប្រមាណ ៣៨ថ្ងៃ ដំណាក់កាល ដង្កូវ

- បន្ទាប់មកដង្កូវនេះបង្កើតជារន្ធដែលមានអង្កត់ផ្ចិតពី ៥-៨ម.ម ហើយវាចេញមកខាងក្រៅដើម្បីបន្តដំណាក់កាលដុកឌឿនៅក្នុងដី

**លក្ខណៈបំផ្លាញ**

- កូនដង្កូវទើបញាស់វារស់នៅលើសំបកទុរេនបរិវេនជិតសណ្តង់ បន្ទាប់មកចាប់ផ្តើមចោះចូលទៅក្នុងផ្លែស៊ីផ្លែ
- ដង្កូវនេះបានចោះចូលទៅក្នុងគ្រាប់ហើយវាធ្វើឱ្យសាច់ខ្លែបជាប់ជាមួយអាចម៍ដង្កូវ



**វិធានការគ្រប់គ្រង និងកម្ចាត់**

- ប្រើអន្ទាក់ពន្លឺ ដើម្បីកាត់បន្ថយចំនួនមេអំបៅពេញវ័យ
- ដុត ឬកប់ផ្លែដែលខូច ឬជ្រុះ
- កាត់ផ្លែដែលនៅជាប់ឱ្យនៅតែមួយ ព្រោះមេអំបៅពេញវ័យចូលចិត្តពងនៅលើសំបករវាងផ្លែឈើដែលនៅជាប់គ្នា។ បើមិនដូច្នេះទេ ត្រូវញែកផ្លែឈើដែលនៅជាប់គ្នាដោយដាក់ឈើ ឬសម្ភារៈណាមួយនៅចន្លោះពួកវា។
- ប្រើថង់ប្លាស្ទិចខ្ចប់ផ្លែ នៅពេលផ្លែអាយុបាន២-៣សប្តាហ៍ដោយប្រើថង់ផ្លាស្ទិចដែលមានរន្ធដើម្បីបង្ហូរទឹក ថង់នឹងការពារមេអំបៅញីពីការពងនៅលើសំបក។ ដកថង់ទាំងនេះចេញ២សប្តាហ៍មុនពេលប្រមូលផលពីព្រោះផ្លែឈើដែលវេចខ្ចប់មានពណ៌ស្លេកខុសពីធម្មជាតិ។

- ក្នុងករណីមានការបំផ្លាញធ្ងន់ធ្ងរយើងអាចកម្ចាត់ដោយប្រើថ្នាំកសិកម្ម ដែលមានសារធាតុសកម្មដូចជា៖ Dimethoate, Emamectin benzoate, Lamda-cyhalothrin, Deltamethrin, Chlorpyrifos , *Bacillus thuringiensis* var. kurstaki ។

## ១.៧ ដង្កូវស៊ីរូងដើមទុរេន

**ឈ្មោះទូទៅជាភាសាខ្មែរ** ៖ ដង្កូវស៊ីរូងដើមទុរេន

**ឈ្មោះទូទៅជាភាសាអង់គ្លេស** ៖ Durian stem borer

**ឈ្មោះវិទ្យាសាស្ត្រ** ៖ *Batocera rufomaculata* DeGeer

**លក្ខណៈរូបសាស្ត្រ**

- ដង្កូវស៊ីរូងដើម គឺជាសត្វល្អិតចង្រៃដ៏ចម្បងទៅលើដំណាំទុរេន ដោយវាស៊ីរូងទៅខាងក្នុងសាច់ឈើ ដែលអាចឱ្យ ដើមទុរេចងាប់បាន
- សត្វពេញវ័យជាទូទៅមានប្រវែងពី ៣ ទៅ ៥ស.ម ហើយវាមានពណ៌ត្នោតក្រម៉ៅ ហើយអាចទំលាក់ពងបានប្រមាណ ២៥ពង
- ដង្កូវមានពណ៌ដូចគ្រីម នឹងក្បាលមានពណ៌ត្នោតក្រម៉ៅ និងមានប្រវែង ១០ស.ម
- វាធ្វើការពងដាក់ក្នុងសំបករយៈពេល ៧-១៣ថ្ងៃទើបញាស់ ហើយដំណាក់កាលដុកឌឿមានរយៈពេល២៨០ ថ្ងៃ

**លក្ខណៈបំផ្លាញ**

- ដង្កូវស៊ីរូងចូលទៅក្នុងសាច់ឈើ បណ្តាលឱ្យដើមទុរេនហូរជ័រ និងដង្កូវស៊ីជាលិកាជួរអែម
- នៅកន្លែងស្នាមបំផ្លាញនឹងមានរន្ធតូចដែលមានជាតិជ័រចេញមកក្រៅ និងមានពណ៌ត្នោត ហើយប្រែទៅជាពណ៌ខ្មៅ
- ដង្កូវដែលទើបនឹងញាស់ចាប់ផ្តើមរកស៊ីសំបកនៅជុំវិញខ្លួនវា



**វិធានការគ្រប់គ្រង និងកម្ចាត់**

- តាមដានវត្តមានការនៃហូរជ័ររបស់ដើម
- ធ្វើការសម្អាតស្មៅ និងរុក្ខជាតិចង្រៃចេញពីចម្ការ។
- ធ្វើការកាត់សម្អាតមែកតូចៗផ្នែកខាងក្នុងដើម មែកដែលងាប់(ស្ងួត) ដុតបំផ្លាញចោល
- ដាក់អន្ទាក់អំពូលភ្លើងដើម្បីចាប់មេពេញវ័យ។
- ពិនិត្យស្វែងរកកន្លែងដែលទើបបំផ្លាញថ្មីៗដោយចោះចាប់ដង្កូវមកកម្ទេចចោល។ ប៉ុន្តែកន្លែងដែលមានការបំផ្លាញដោយដង្កូវប្រភេទនេះម្ចាស់ចំការត្រូវចាំថាការចោះ ឬកាប់ដើម្បីចាប់ដង្កូវត្រូវធ្វើយ៉ាង ណាឱ្យមុខរបួស ឬកន្លែងដែលត្រូវចោះនោះឱ្យមានមុខតូចបំផុតដែលអាចធ្វើទៅបាន ព្រោះដើម្បីកាត់បន្ថយស្លាកស្នាមនៃរបួសដែលជាហេតុបង្កដល់ការឆ្លងនៃមេរោគ។ កន្លែងដែលបានចោះ ឬកាប់ រួចចាំបាច់ត្រូវលាបថ្នាំការពារផ្សិត។
- លាបកំបោរស ឬលាបល្បាយ Bordeau ដោយលាយជាមួយថ្នាំកម្ចាត់សត្វល្អិតលាបលើដើមកំពស់ពីដី១,៥ម៉ែត្រ។
- ដើម្បីកម្ចាត់ដង្កូវស៊ីរូងដើមទុរេនយើងអាចបាញ់ថ្នាំកម្ចាត់សត្វល្អិតដែលមានសារធាតុសកម្មមួយចំនួន ដូចជា Chlorpyrifos, Cypermethrin ចូលតាមកន្លែងដែលបំផ្លាញទាំងនោះ។

## ២. ជំងឺចំបងៗលើដំណាំទុរេន

### ២.១ ជំងឺដំបៅដើម

**ឈ្មោះទូទៅជាភាសាខ្មែរ** ៖ ជំងឺដំបៅដើម

**ឈ្មោះទូទៅជាភាសាអង់គ្លេស** ៖ Stem canker

**ឈ្មោះវិទ្យាសាស្ត្រ** ៖ *Phytophthora palmivora*

### លក្ខណៈរូបសាស្ត្រ

- ជំងឺដំបៅដើមនេះ ជាប្រភេទផ្សិតនៅក្នុងដី ដែលវាមានស្ប៉រចំនួន៤ប្រភេទ ដែលអាចបង្កជំងឺដោយផ្ទាល់ ឬដោយប្រយោលដែលអាចធ្វើការបំផ្លាញស្លឹក ដើម និងឫស
- ពួកវាអាចរីករាលដាលតាមរយៈដី ទឹកក្នុងដី និងនៅពេលភ្លៀងធ្លាក់ហើយមានខ្យល់បក់ខ្លាំង

### លក្ខណៈបំផ្លាញ

- រោគសញ្ញាជំងឺនេះដំបូង ចាប់ផ្ដើមដោយសារតែការហូរជ័រចេញពីស្នាមរបួស ស្នាមប្រេះនៃសំបក និងរន្ធរបស់ដង្កូវចោះ
- បន្ទាប់មកស្នាមរបួសនេះចាប់ផ្ដើមរីករាលដាលធំនៅលើដើមទាំងមូល
- ក្រោយមកមែករបស់វាចាប់ផ្ដើមងាប់ រហូតដល់ងាប់ដើមទាំងស្រុង
- ជាទូទៅជំងឺនេះបំផ្លាញទៅលើដើមចាស់ៗនៅក្នុងរដូវវស្សា



## វិធានការគ្រប់គ្រង និងកម្ចាត់

វិធីសាស្ត្រគ្រប់គ្រងរួមបញ្ចូលគ្នា គឺត្រូវការជាចាំបាច់ដើម្បីគ្រប់គ្រងជំងឺប្រកបដោយប្រសិទ្ធភាព ការអនុវត្តវិធានគ្រប់គ្រងដំណាំ ការគ្រប់គ្រងជីវសាស្ត្រ និងការប្រើប្រាស់សារធាតុគីមីសមស្រប។ *Trichoderma harzianum* អាចត្រូវបានគេយកទៅប្រើលើផ្ទៃដីជាភ្នាក់ងារប្រឆាំងមេរោគទូទៅនៅក្នុងដី។

ដើម្បីការពារ ឬកាត់បន្ថយជំងឺដែលបង្កឡើងដោយពពួកផ្សិត *Phytophthora* spp. វិធានការការពារ និងវិធីសាស្ត្រគ្រប់គ្រងរួមបញ្ចូលគ្នាគួរតែត្រូវបានអនុវត្ត។ វិធានការទាំងនេះរួមមានដូចខាងក្រោម៖

- ប្រើប្រាស់កូនពូជដាំដុះដែលបង្កាត់តាមរយៈក្លូនដែលធន់ទ្រាំ
- ប្រើកូនពូជដែលមានការធានាថាវាគ្មានជំងឺ
- ជ្រើសរើសទីតាំងដែលសមស្របដើម្បីធ្វើការដាំដុះ
- ជ្រើសរើសវិធីសាស្ត្រដាំដុះឱ្យបានត្រឹមត្រូវ (លើកដីជាទួល)
- ពិនិត្យគុណភាពដី (PH 5.5-6.5)
- ប្រើប្រាស់ជីទ្រាប់បាតត្រឹមត្រូវ
- បង្កើតប្រព័ន្ធបង្ហូរទឹកក្នុងចម្ការឱ្យបានល្អដោយសារផ្សិតប្រភេទនេះ ចូលចិត្តលក្ខខណ្ឌមានសំណើម។
- កាត់មែកទាបបំផុតដើម្បីការពារការកើតឡើងនៃលក្ខខណ្ឌសើម។
- ប្រើប្រាស់ជីសរីរាង្គ និងគីមីឱ្យបានត្រឹមត្រូវ ដើម្បីបង្កើនជីវជាតិដល់ដី ជួយឱ្យទុរេនមានសុខភាពល្អធន់ទៅនឹងជំងឺ។
- ផ្តល់ការថែទាំឱ្យបានដិតដល់តាមរយៈការស្រោចស្រព ការសម្អាត់ស្មៅ ការបន្ថែមសារធាតុចិញ្ចឹម ការចម្រើនដីតាមគល់ដំណាំ ការតាមដានវត្តមាននៃការបំផ្លាញរបស់សត្វល្អិត និងជំងឺចង្រៃផ្សេងៗជាដើម
- ជៀសវាងការខូចខាតជាលិកាដើម ដោយសារការរងរបួសធ្វើឱ្យរុក្ខជាតិងាយឆ្លងនឹងកើតជំងឺ។

- សម្រាប់ដើមដែលចាប់ផ្តើមរងការបំផ្លាញដោយជំងឺនេះ កុំឱ្យរាលដាលរហូតដល់ទុរេនងាប់ដើមទាំងស្រុង យើងត្រូវចិតសំបកត្រង់បរិវេនមានស្នាមដំបៅចេញជាមុនសិន បន្ទាប់មកយើងលាបថ្នាំគីមីកសិកម្មពេញបរិវេនដែលមានដំបៅនោះ។
- ការអនុវត្តវិធានអនាម័យចម្ការតាមរយៈ ការដុតបំផ្លាញចោលនូវរាល់ផ្នែកសរីរាង្គដែលរងការបំផ្លាញពីជំងឺដូចជា ផ្លែ មែក និងដើមជាដើម។
- ចំពោះការប្រមូលផលជៀសវាងការធ្លាក់ដែលនាំឱ្យមានរបួសស្នាមដល់ផ្លែជាហេតុនាំឱ្យមានការឆ្លងមេរោគ។
- ការពារ និងកម្ចាត់ជំងឺប្រភេទនេះយើងអាចប្រើប្រាស់ថ្នាំគីមីកសិកម្មដែលមានសារធាតុសកម្មដូចជា Metalaxyl, Dimethomorph , Fosetyl-aluminium, Pyraclostrobin ដើម្បីបាញ់ និងស្រោចតាមបរិវេណជុំវិញគល់ដំណាំ។
- បាញ់ថ្នាំការពារផ្សិតរៀងរាល់ ១៥ថ្ងៃក្នុងរដូវវស្សា ឬតាមស្ថានភាពជាក់ស្តែងនៃការបំផ្លាញរបស់ផ្សិតចង្រៃ។

## ២.២ ជំងឺផ្សិតហ្វូម៉ូស៊ីសរលាកស្លឹក

**ឈ្មោះទូទៅជាភាសាខ្មែរ** ៖ ជំងឺផ្សិតហ្វូម៉ូស៊ីសរលាកស្លឹក

**ឈ្មោះទូទៅជាភាសាអង់គ្លេស** ៖ Phomopsis leaf blight

**ឈ្មោះវិទ្យាសាស្ត្រ** ៖ *Phomopsis durionis*

### លក្ខណៈរូបសាស្ត្រ

- ជាទូទៅជំងឺនេះកើតឡើងនៅក្នុងលក្ខណ្ឌសំណើម និងសីតុណ្ហភាពក្តៅល្មម
- ដូច្នេះនៅពេលផ្តល់ទឹក ទៅលើកូនដំណាំដែលនៅចង្អៀតគ្នានោះគឺជាលក្ខខណ្ឌដ៏ល្អ ដល់ការរីករាលដាលរបស់ជំងឺនេះ

លក្ខណៈបំផ្លាញ

- ជាជំងឺចម្បងលើដំណាំកូនទុរេន
- វាបង្កើតស្នាមពណ៌ត្នោត ឬប្រផេះស្រាល ដែលមានគែមពណ៌ត្នោតក្រម៉ៅនៅលើស្លឹករបស់ដំណាំ




**វិធានការគ្រប់គ្រង និងកម្ចាត់**

- រៀបចំទុកដាក់កូនដំណាំឱ្យមានគំលាតសមស្រប
- បាញ់ថ្នាំការពារ និងកម្ចាត់ផ្សិតចង្រៃលើកូនដំណាំដើម្បីប្រាកដថាកូនដំណាំមិនមានការបំផ្លាញពីជំងឺផ្សេងៗមុននឹងធ្វើការដាំដុះ
- ជ្រើសរើសកូនដំណាំដែលមិនមានសញ្ញានៃការបំផ្លាញរបស់ជំងឺ
- ជ្រើសរើសវិធីសាស្រ្តដាំដុះឱ្យបានត្រឹមត្រូវ
- ប្រើប្រាស់សារធាតុចិញ្ចឹមទៅតាមដំណាក់កាលលូតលាស់របស់ដំណាំដើម្បីឱ្យដំណាំមានសុខភាពរឹងមាំធន់នឹង កត្តាចង្រៃផ្សេងៗ
- ប្រើប្រាស់ផ្សិតជីវសាស្រ្តទ្រីកូឌឺម៉ាកូនីនជី លាយជាមួយជីកំប៉ុស្តិ៍ ដើម្បីការពារកុំឱ្យមេរោគផ្សិតរីករាលដាល
- ដើម្បីទប់ស្កាត់ និងព្យាបាលជំងឺនេះយើងអាចប្រើប្រាស់ថ្នាំកសិកម្មដែលមានសារធាតុសកម្មដូចជា Prochloraz, Metalaxyl, Fosetyl-aluminium, Chlorothalonil, និងពពួក Copper។

## ២.៣ ជំងឺកុលាប

**ឈ្មោះទូទៅជាភាសាខ្មែរ** ៖ ជំងឺកុលាប

**ឈ្មោះទូទៅជាភាសាអង់គ្លេស** ៖ Pink Disease

**ឈ្មោះវិទ្យាសាស្ត្រ** ៖ *Erythricium salmonicolor*

### លក្ខណៈរូបសាស្ត្រ

- ជំងឺនេះបណ្ដាលមកពីជំងឺផ្សិត *Erythricium salmonicolor* (anamorph: Necator decretus)
- ដែលវាបង្កើតជាសសៃមីសេដ្យូមពណ៌ស៊ីជម្ពូចាក់ចូលក្នុងដើម ឬមែកដែលមានទំហំ ១មម.
- សសៃមីសេដ្យូម ដែលចាស់ប្រែពណ៌ទៅជាសំបកពណ៌ផ្កាឈូក បន្ទាប់មកសំបកនេះក៏ប្រេះបែកទៅតាមអាកាសធាតុ

### លក្ខណៈបំផ្លាញ

- ជំងឺនេះធ្វើការបំផ្លាញទៅលើមែកខ្ចីដែលទើបដុះ
- ធ្វើឱ្យស្លឹកស្រពោននឹងងាប់
- ការរីករាលដាលនៃជំងឺនេះកើតឡើងដោយសារដំណក់ទឹកភ្លៀង
- និងតាមកម្លាំងខ្យល់បក់នៅពេលដែលសសៃមីសេល្យូមទៅប៉ះនឹងសំបកដើមដែលសើមបន្ទាប់មកផ្សិតនៃជំងឺនេះចាប់ផ្ដើមដុះលូតលាស់នឹងធ្វើការបំផ្លាញទៅលើដំណាំ។



**វិធានការគ្រប់គ្រង និងកម្ចាត់**

- ដាំដុះឱ្យមានគម្លាតសមស្រប
- ជំងឺផ្សិតកុលាបអាចត្រូវបានគ្រប់គ្រងដោយការកាត់មែកឈើដែលមានមេរោគ ហើយព្យាបាលមុខរបួសដោយថ្នាំសម្លាប់ផ្សិត។
- ការប្រើប្រាស់ថ្នាំដែលមានទំរង Copper ដូចជាល្បាយ (Borderu, copper oxychloride, copper carbonate) បានផ្តល់ការការពារពីជំងឺផ្សិតកុលាប។ ការអនុវត្តន៍គួរបាញ់១ទៅ៣ដងក្នុងមួយឆ្នាំនៅក្នុងកំឡុងខែមករា ឧសភា និងកញ្ញា។

**២.៤ ជំងឺរលួយឫស**

**ឈ្មោះទូទៅជាភាសាខ្មែរ** ៖ ជំងឺរលួយឫស

**ឈ្មោះទូទៅជាភាសាអង់គ្លេស** ៖ Root rot

**ឈ្មោះវិទ្យាសាស្ត្រ** ៖ *Phytophthora palmivora*

**លក្ខណៈរូបសាស្ត្រ**

- ជំងឺរលួយឫសជាជំងឺដែលបង្កឡើងដោយផ្សិតឈ្មោះ *Phytophthora palmivora*
- ជាទូទៅជំងឺនេះកើតឡើង និងមានផលប៉ះពាល់ខ្លាំងនៅពេលដែលមានភ្លៀងធ្លាក់ខ្លាំង
- មានសំណើមខ្ពស់ ហើយអាចសាយភាយតាមរយៈខ្យល់ទៅកាន់ស្លឹក មែក និងផ្លែ

**លក្ខណៈបំផ្លាញ**

- ជំងឺនេះធ្វើការបំផ្លាញទៅលើប្រព័ន្ធឫសរបស់ទុរេន
- ធ្វើឱ្យឫសទុរេនឡើងពណ៌ត្នោតហើយរលួយ

- រោគសញ្ញារបស់វាគឺធ្វើឱ្យមានស្នាមជាំទឹក ជាមួយនឹងស្នាមទឹកហូរនៅនឹងគល់របស់ដំណាំ
- សាច់ឈើនឹងសំបកប្រែទៅជាពណ៌ត្នោតក្រម៉ៅ
- ប្រសិនបើវាកើតលើគល់ទាំងមូល នោះស្លឹកទាំងអស់នឹងជ្រុះ បន្ទាប់មកដើមក៏ងាប់







**វិធានការគ្រប់គ្រង និងកម្ចាត់**

- ប្រើប្រាស់កូនពូជដែលមានសុខភាពល្អ គ្មានជំងឺ
- ជ្រើសរើសទីតាំងដែលសមស្របដើម្បីធ្វើការដាំដុះ
- ជ្រើសរើសវិធីសាស្ត្រដាំដុះឱ្យបានត្រឹមត្រូវ (លើកដីជាទួល)
- ពិនិត្យគុណភាពដី (PH 5.5-6.5)
- ប្រើប្រាស់ជីទ្រាប់បាតត្រឹមត្រូវ
- បង្កើតប្រព័ន្ធបង្ហូរទឹកក្នុងចម្ការឱ្យបានល្អដោយសារផ្សិតនេះចូលចិត្តលក្ខខណ្ឌមានសំណើម។
- កាត់មែកទាបបំផុតដើម្បីការពារការកើតឡើងនៃលក្ខខណ្ឌសើម។
- ប្រើប្រាស់ជីសរីរាង្គ និងគីមីឱ្យបានត្រឹមត្រូវ ដើម្បីបង្កើនជីវជាតិដល់ដីជួយឱ្យទុរេនមានសុខភាពល្អធន់ទៅនឹងជំងឺ។

- ផ្តល់ការថែទាំឱ្យបានជិតដល់តាមរយៈការស្រោចស្រព ការសម្អាត់ស្មៅ ការបន្ថែមសារធាតុចិញ្ចឹម ការចម្រើនជីតាមគល់ដំណាំ ការតាមដានវត្តមាននៃការបំផ្លាញរបស់សត្វល្អិត និងជំងឺចង្រៃផ្សេងៗជាដើម
- ជៀសវាងការខូចខាតជាលិកាដើម ដោយសារការរងរបួសធ្វើឱ្យរុក្ខជាតិងាយឆ្លង និងកើតជំងឺ។
- សម្រាប់ដើមដែលចាប់ផ្តើមរងការបំផ្លាញដោយជំងឺនេះ កុំឱ្យរាលដាលរហូតដល់ទុរេនងាប់ដើមទាំងស្រុង យើងត្រូវចិតសំបកត្រង់បរិវេណមានស្នាមដំបៅចេញជាមុនសិន បន្ទាប់មកយើងលាបថ្នាំកសិកម្មពេញបរិវេណដែលមានដំបៅនោះ។
- ការអនុវត្តវិធានអនាម័យចម្ការតាមរយៈការដុតបំផ្លាញចោលនូវរាល់ផ្នែកសរីរាង្គដែលរងការបំផ្លាញពីជំងឺដូចជា ផ្លែ មែក និងដើមជាដើម។
- ចំពោះការប្រមូលផលជៀសវាងការធ្លាក់ដែលនាំឱ្យមានរបួសស្នាមដល់ផ្លែជាហេតុនាំឱ្យមានការឆ្លងមេរោគ។
- ការពារ និងកម្ចាត់ជំងឺប្រភេទនេះ យើងអាចប្រើប្រាស់ថ្នាំកសិកម្មដែលមានសារធាតុសកម្មដូចជា Metalaxyl, Dimethomorph , Fosetyl-aluminium, Pyraclostrobin ដើម្បីបាញ់ និងស្រោចតាមបរិវេណជុំវិញគល់ដំណាំ។
- បាញ់ថ្នាំការពារផ្សិតរៀងរាល់ ១៥ ថ្ងៃក្នុងរដូវវស្សា ឬតាមស្ថានភាពជាក់ស្តែងនៃការបំផ្លាញរបស់ផ្សិតចង្រៃ។

## ២.៥ ជំងឺផ្សិតអង់ត្រាណូសស្លឹកទុរេន

**ឈ្មោះទូទៅជាភាសាខ្មែរ** ៖ ជំងឺផ្សិតអង់ត្រាណូសស្លឹកទុរេន

**ឈ្មោះទូទៅជាភាសាអង់គ្លេស** ៖ Durian leaf antracnose

**ឈ្មោះវិទ្យាសាស្ត្រ** ៖ *Colletotrichum gloeosporoides*

### លក្ខណៈរូបសាស្ត្រ

- ជំងឺផ្សិតនេះបណ្តាលមកពីភ្នាក់ងារបង្ករោគ *Colletotrichum gloeosporoides*
- សកម្មភាពជំងឺអាស្រ័យទៅលើលក្ខខណ្ឌអាកាសធាតុ និងសីតុណ្ហភាព៖ សំណើមបរិយាកាសខ្ពស់ ៩៥% និងសីតុណ្ហភាព ២៥-២៨ អង្សាសេ
- ប្រសិនបើជាប្រជាករជំងឺផ្សិតនេះច្រើន វាអាចឆ្លងពីស្លឹក ទៅផ្កា ពីផ្កាទៅផ្លែផងដែរ។

### លក្ខណៈបំផ្លាញ

- វាបំផ្លាញនៅលើផ្នែកស្លឹក ផ្កា និងផ្លែ
- មានរាងជារង្វង់ដាច់ពីគ្នាស្នាមមានពណ៌ប្រផេះស្រាល ឬ ត្នោតស្លេក
- លក្ខណៈជាស្លឹកងាប់ ព័ទ្ធជុំវិញដោយវ័ណ្ឌពណ៌ខ្មៅ ឬ ត្នោតចាស់
- ជាទូទៅកើតនៅចុងស្លឹក



**វិធានការគ្រប់គ្រង និងកម្ចាត់**

ដើម្បីការពារ ឬកាត់បន្ថយជំងឺដែលបង្កឡើងដោយពពួកផ្សិតនេះ វិធានការការពារ និងគ្រប់គ្រងរួមបញ្ចូលគ្នាគួរតែត្រូវបានអនុវត្ត។ វិធានការទាំងនេះរួមមានដូចខាងក្រោម៖

- ជ្រើសរើសតំបន់ដាំដុះសមស្រប
- ជ្រើសរើសកូនពូជដែលគ្មានការបំផ្លាញពីសមាសភាពចង្រៃផ្សេង
- ត្រូវក្ជួររាស់សម្អាតស្មៅ និងកាកសំណល់ដំណាំផ្សេងៗឱ្យបានស្អាតល្អ
- ត្រូវដាំឱ្យមានគម្លាតដើមសមស្រប
- ផ្តល់សារធាតុចិញ្ចឹមឱ្យបានត្រឹមត្រូវ (ជៀសវាងការប្រើអាសូតលើសកម្រិត) ដើម្បីបង្កើនភាពរឹងមាំដល់ដំណាំ
- អាចកាត់តាក់តែងមែកតូចៗផ្នែកខាងក្នុងដើមចេញខ្លះដើម្បីរក្សាតុល្យភាពសំណើមក្នុងបរិវេណដើមឲ្យមានពន្លឺចេញចូល
- នៅរាល់ពេលដំណាក់កាលលូតលាស់ខ្លាំងនៃស្លឹក និងពន្លកខ្ចីយើងអាចប្រើថ្នាំផ្សិតកសិកម្មដែលមាន សារធាតុសកម្មដូចជា Propineb, Chlorothalonil, Maneb ដើម្បីការពារ និងប្រើ Prochloraz, Difenoconazole, Azoxystrobin ដើម្បីព្យាបាល។

## ៣. ឯកសារយោង


១. សទ្ទានុក្រមសមាភាពចង្រៃលើដំណាំសំខាន់ៗជាភាសាខ្មែរ នាយកដ្ឋានការពារដំណាំ អនាម័យ និងភូតគាមអនាម័យ, អគ្គនាយកដ្ឋានកសិកម្ម ឆ្នាំ២០១៩

២. https://thepwatana.com/en/blog/durian-pest-thrips/

៣. https://www.cropsreview.com/phytophthora/

៤. https://www.cropsreview.com/phytophthora/

៥. https://thepwatana.com/en/blog/durian-pest-african-red-mite/

៦. https://www.sciencedirect.com/science/article/abs/pii/0261219494901090

៧. CAB International. 2011. *Conogethes puctiferalis* datasheet. In: Crop Protection Compendium. Wallingford, UK: CAB International.

៨. Veeranee, T., Pattavipha, S., Somsiri, S. 2016. Leaf spot characteristics of phomopsos durionis on durian and latent infection of the pathogen. ACTA. Vol. 64.